Australian Government
Department of Social Services



# អាពាហ៍ពិពាហ៍ដោយបង្ខំ និងមិនគ្រប់អាយុ

## ការបង្ខំឲ្យជនណាម្នាក់រៀបការ គឺជាបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរមួយនៅក្នុងប្រទេសអូស្ត្រាលី

នៅប្រទេសអូស្ត្រាលី មនុស្សមានសេរីភាពក្នុងការសម្រេចចិត្តរៀបការ។ ជាធម្មតា បុរស ឬស្ត្រីត្រូវមានអាយុលើស **18** ឆ្នាំដើម្បីរៀបការស្របច្បាប់។ នៅក្នុងកាលៈទេសៈខ្លះ ជនណាម្នាក់ដែលមានអាយុលើស 16 ឆ្នាំអាចរៀបការបាន ក៏ប៉ុន្តែតម្រូវឲ្យមានសាលក្រមតុលាការ។

ជននោះត្រូវយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយគ្មានការបង្ខិតបង្ខំ ឬល្បិចកល។

អាពាហ៍ពិពាហ៍ដោយបង្ខំគឺខុសពីអាពាហ៍ពិពាហ៍រៀបចំទុក ដែលមនុស្សទាំងពីរនាក់យល់ព្រមទទួលយកតាមសិទ្ធិសេរីភាពរបស់ពួកគេ។ អាពាហ៍ពិពាហ៍រៀបចំទុកមានលក្ខណៈស្របច្បាប់នៅប្រទេសអូស្ត្រាលី។

> ប្រសិនបើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ សូមទូរស័ព្ទទៅប៉ូលីសលេខ **000**។
> ប៉ូលីសនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយអាចទុកចិត្តបាន។
>
> សម្រាប់ការប្រឹក្សាយោបល់ និងការផ្តត់ផ្គង់ជាសម្ងាត់ ហើយឥតគិតថ្លៃ សូមទូរស័ព្ទ 1800 RESPECT លេខ **1800 737 732**។
>
> ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដោយឥតគិតថ្លៃ សូមទូរស័ព្ទលេខ **131 450**។

## ការយក ឬបញ្ជូនជនណាម្នាក់ដើម្បីឲ្យរៀបការដោយបង្ខំនៅក្នុងប្រទេសមួយផ្សេងទៀត ឬឲ្យជនណាម្នាក់រៀបចំអាពាហ៍ពិពាហ៍បែបដូចនេះ គឺជាអំពើខុសច្បាប់

អាពាហ៍ពិពាហ៍ដោយបង្ខំ និងមិនគ្រប់អាយុ ជួនកាលជាប់ពាក់ព័ន្ធនឹងការបញ្ជូនមនុស្សទៅប្រទេសមួយផ្សេងៗទៀត ឬឆ្លងដែនដោយផ្ទុយនឹងឆន្ទៈរបស់ពួកគេ ហើយការធ្វើបែបនេះគឺប្រឆាំងនឹងច្បាប់។

## តើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ឬ?

សូមទូរស័ព្ទទៅប៉ូលីសសហព័ន្ធអូស្ត្រាលី (AFP) លេខ **131 237**។ AFP អាចផ្តល់យោបល់បឋម និងបញ្ជូនជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងមិនគ្រប់អាយុ ឬការជួញដូរមនុស្សទៅរកការគាំពាររួមមានកន្លែងស្នាក់អាស្រ័យ ជំនួយហិរញ្ញវត្ថុ ការផ្តល់ប្រឹក្សា និងយោបល់ផ្នែកច្បាប់។

សម្រាប់ព័ត៌មានបន្ថែម សូមមកមើលតាមតំណភ្ជាប់ទៅវិបសាយរបស់ AFP នៅត្រង់ **www.afp.gov.au**។

## មានសេវាផ្សេងៗទៀតក្នុងប្រទេសអូស្ត្រាលីដែលអាចជួយបាន

**1800 RESPECT** គឺជាសេវាផ្តល់ការប្រឹក្សាអំពីការរំលោភបំពានខាងផ្លូវភេទ អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ ទូទាំងប្រទេសរបស់ប្រទេសអូស្ត្រាលី។ សេវានេះផ្តល់ព័ត៌មាន និងប្រឹក្សាតាមអ៊ីនធើណិត និងទូរស័ព្ទដោយសម្ងាត់ ហើយឥតគិតថ្លៃ។ អ្នកផ្តល់ការប្រឹក្សានឹងស្តាប់អ្នក ឆ្លើយសំណួរ និងអាចបញ្ជូនអ្នកទៅកាន់សេវាជំនួយផ្សេងៗទៀតនៅតាមតំបន់ដែលអ្នករស់នៅ។

សូមទូរស័ព្ទលេខ **1800 737 732** ឬបើកចូលវិបសាយរបស់ 1800 RESPECT នៅត្រង់ **www.1800RESPECT.org.au**។

## តើអ្នកត្រូវការអ្នកបកប្រែភាសាឬទេ?

សូមទូរស័ព្ទទៅសេវាបកប្រែភាសាសរសេរ និងនិយាយ (TIS) ដោយឥតគិតថ្លៃ លេខ **131 450**។ TIS អាចជួយអ្នកឲ្យប្រាស្រ័យទាក់ទងជាមួយសេវាផ្សេងៗទៀតបាន។ TIS មិនផ្តល់ការប្រឹក្សាទេ។

## សម្រាប់ព័ត៌មានបន្ថែមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការជួញដូរមនុស្ស

សូមរកមើលតាមការតភ្ជាប់ទៅវិបសាយរបស់ការិយាល័យអគ្គមេធាវី (AGD) នៅត្រង់ **www.ag.gov.au**